# សេចក្តីប្រកាសព័ត៌មានរបស់កម្មវិធីស្បៀងអាហារពិភពលោក

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២

## ក្រសួងអប់រំយុវជននិងកីឡា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ និងកម្មវិធីស្បៀងអាហារពិភពលោក ធ្វើទស្សនកិច្ចទៅកាន់ខេត្តកំពង់ឆ្នាំង ដើម្បីអបអរសាទរឆ្នាំសិក្សាថ្មី និងការបើកដំណើរការទាំងស្រុងនូវកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន

**កំពង់ឆ្នាំង៖** ថ្ងៃនេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នាយកប្រចាំប្រទេសនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) និងនាយកប្រចាំប្រទេសនៃកម្មវិធីស្បៀងអាហារពិភពលោក (WFP) បានអញ្ជើញទៅទស្សនកិច្ចនៅតាមសាលារៀនក្នុងខេត្តកំពង់ឆ្នាំង ដើម្បីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្ទះបាយសាលា កន្លែងទទួលទានអាហារ និងសម្ភារបរិក្ខារផ្សេងៗទៀត ដែលផ្តល់មូលនិធិដោយ KOICA ក៏ដូចជាប្រារព្ធការចាប់ផ្តើមឡើងវិញទាំងស្រុងនូវកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន នៅទូទាំងប្រទេសសម្រាប់ឆ្នាំសិក្សាថ្មី។ នៅក្នុងដំណើរទស្សនៈកិច្ចនេះ គណៈប្រតិភូបានអញ្ជើញទៅកាន់សាលាបឋមសិក្សាស្នេត និងសាលាបឋមសិក្សាអង្គសិរី និងត្រូវបានទទួលស្វាគមន៍ពីថ្នាក់ដឹកនាំអាជ្ញាធរមូលដ្ឋានក៏ដូចជាឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំងផងដែរ។

កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀននៅកម្ពុជាត្រូវបានដាក់បញ្ចូលនៅក្នុងក្របខណ្ឌគោលនយោបាយជាតិអប់រំ និងក្របខណ្ឌគោលនយោបាយគាំពារសង្គម ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស តាមការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់កុមារថ្នាក់មត្តេយ្យ និងបឋមសិក្សា លើកកម្ពស់អាហារូបត្ថម្ភនិងសុខភាពរបស់ពួកគេ និងជួយឱ្យពួកគេបានហូបឆ្អែតមួយរយៈពេល ក៏ដូចជា ជួយផ្តល់នូវសំណាញ់សុវត្ថិភាពដល់ក្រុមគ្រួសារដែលងាយរងគ្រោះ តាមរយៈកម្មវិធីផ្ទេរប្រាក់។

អស់រយៈពេលជាង២០ឆ្នាំហើយ កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនបានផ្តល់អាហារដល់កុមារចំនួន ៣២០.០០០នាក់ នៅក្នុងសាលាគោលដៅចំនួន ១.១១៤ នៅក្នុងខេត្តចំនួនដប់។ ការសិក្សាបានបង្ហាញថា អាហារដែលមានជីវជាតិជួយបង្កើនការផ្តោតអារម្មណ៍របស់សិស្ស និងជួយឱ្យការរៀនសូត្ររបស់ពួកគេកាន់តែមានប្រសិទ្ធភាព និងរួមចំណែកលើកកម្ពស់លទ្ធផលនៃការអប់រំ។

ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុនមានប្រសាសន៍ថា «ចាប់តាំងពីកម្មវិធីបានចាប់ផ្តើមមក យើងបានកត់សម្គាល់ឃើញថាអត្រាបោះបង់ការសិក្សានៅសាលាបឋមសិក្សាបានធ្លាក់ចុះ និងមានកំណើនការចូលរៀនទៀងទាត់»។ ឯកឧត្តមរដ្ឋមន្ត្រីមានប្រសាសន៍បន្ថែមផងដែរថា ការផ្តល់អាហារចម្រុះនិងសម្បូរជីវជាតិ នៅ

តាមសាលារៀន ដោយឥតគិតថ្លៃ គឺជាការជំរុញទឹកចិត្តដ៏ខ្លាំងក្លាដល់ក្រុមគ្រួសារ ឱ្យបញ្ជូនកូនទៅសាលារៀន ក៏ដូចជាជួយសម្រាលបន្ទុកសេដ្ឋកិច្ចរបស់ពួកគាត់។

ចាប់តាំងពីដើមឆ្នាំ២០២០មក KOICA បានគាំទ្រកម្មវិធីផ្តល់ស្បៀងអាហារតាមសលារៀននៅក្នុងខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់ ដោយផ្តល់មូលនិធិសរុបចំនួន ១០លានដុល្លារក្នុងរយៈពេលបួនឆ្នាំ។ ជំនួយនេះបានអនុញ្ញាតឱ្យមានការសាងសង់ផ្ទះបាយ កន្លែងទទួលទានអាហារ និងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតនិងអនាម័យ នៅតាមសាលារៀនជាច្រើន ដើម្បីសម្រួលដល់ការផ្តល់អាហារតាមសាលារៀនប្រកបដោយសុវត្ថិភាព អនាម័យ និងមានប្រសិទ្ធភាព។

KOICA ក៏បានគាំទ្រជាពិសេសដល់កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនដោយប្រើប្រាស់"កសិផលក្នុងសហគមន៍" ដែលទិញផលិតផលស្បៀងក្នុងស្រុកសម្រាប់យកមកប្រើប្រាស់ក្នុងការរៀបចំអាហារនៅសាលា។ កម្មវិធីនេះផ្សារភ្ជាប់ការផ្តល់អាហារតាមសាលាទៅនឹងការកែលម្អអាហារូបត្ថម្ភ សុខុមាលភាព និងការអភិវឌ្ឍជនបទ ដោយការជំរុញកំណើនកសិកម្ម និងសន្តិសុខស្បៀងក្នុងតំបន់ ក៏ដូចជាត្រួសត្រាយផ្លូវសម្រាប់ការរៀបចំកែប្រែកម្មវិធីនេះឱ្យទៅជាកម្មវិធីជាតិផងដែរ។

លោកស្រី ក្លែរ កូណាន់ តំណាងកម្មវិធីស្បៀងអាហារពិភពលោក និងជានាយកប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា "យើងសូមថ្លែងអំណរគុណចំពោះ KOICA សម្រាប់ការគាំទ្រដល់កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន។ ពួកគាត់មានភាពបត់បែន និងគិតគូរពីអនាគតទៅមុខ ជាពិសេសមានគំនិតផ្តួចផ្តើមក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជាលក្ខណៈស្តង់ដារនៅតាមសាលារៀន ដើម្បីជួយសម្រួលដល់ការអនុវត្តកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព។ កុមារនៅសាលាទាំងនេះមិនចាំបាច់ញ៉ាំអាហារក្នុងថ្នាក់ ឬក្នុងទីធ្លាបរិវេណសាលាទៀតទេ។"

ក្នុងអំឡុងពេលដែលសាលារៀនបានបិទដោយសារជំងឺរាតត្បាត KOICA បានព្រមព្រៀងឱ្យផ្លាស់ប្តូរពីការផ្តល់ស្បៀងតាមសាលារៀន ទៅជា ការចែកស្បៀងដល់ក្រុមគ្រួសារសិស្សក្រីក្រ ជាបណ្តោះអាសន្ន ក្នុងគោលបំណងបន្តផ្តល់អាហារូបត្ថម្ភដើម្បីជួយឱ្យកុមារបន្តការសិក្សានៅផ្ទះ។

ឥឡូវនេះសាលាបានបើកដំណើរការឡើងវិញទាំងស្រុងសម្រាប់ឆ្នាំសិក្សាថ្មី កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនក៏ចាប់ផ្តើមឡើងវិញដែរ ដើម្បីធានាថា កុមារទទួលបានអាហារមានជីវជាតិយ៉ាងតិចមួយដង ក្នុងមួយថ្ងៃ ដើម្បីគាំទ្រដល់ការសិក្សា និងការអភិវឌ្ឍរបស់ពួកគេ។

លោក RHO Hyunjun នាយកប្រចាំប្រទេសរបស់ KOICA មានប្រសាសន៍ថា "យើងមានសេចក្តីរីករាយណាស់ដែលកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនដោយប្រើប្រាស់កសិផលសហគមន៍អាចដំណើរការឡើងវិញបានពេញលេញ ដោយធានាថាកុមារអាចទៅសាលារៀន ទទួលបានអាហារមានជីវជាតិ និងបានរៀនសូត្រអស់ពីសមត្ថភាពរបស់ពួកគេ។"

"ការអប់រំមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសមួយ ហើយយើងមិនចង់ទុកឱ្យកុមារណាម្នាក់ណាចោលនោះទេ។ យើងសង្ឃឹមថា ការរួមចំណែកមួយផ្នែកតូចនេះនឹងរួមចំណែកដល់កិច្ចការនេះ។"

កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់កម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ទាមទារឱ្យមានការអភិវឌ្ឍន៍ធនធានមនុស្សបន្ថែមទៀត ដើម្បីបំពេញតម្រូវការជំនាញសម្រាប់ទីផ្សារនាពេលអនាគត។ កង្វះអាហារូបត្ថម្ភនៅតែជាកង្វល់ផ្នែកសុខភាពសាធារណៈ ជាឧទាហរណ៍ អត្រាក្រិសក្រិនមានដល់ទៅ៣២%ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ។ កម្មវិធីផ្តល់អាហារដល់សាលារៀនរួមចំណែកផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ក៏ដូចជាសម្រាប់កុមារដែលទទួលបានអាហារផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង (អ៊ីម៉ែល chou.chea@wfp.org)៖**
លោកស្រី ជា ជូ មន្ត្រីគ្រប់គ្រងផ្នែកទំនាក់ទំនងនិងរបាយការណ៍
កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា
ទូរស័ព្ទលេខ៖ **+855 78 565 283**